# ការធ្វើលទ្ធកម្មគ្រាប់ពូជរបស់ប្រភេទឈើមួយចំនួន

**១-ប្រភេទធ្នង់:** (*Pterocarpus macrocarpus*)

**ក-លក្ខណៈទូទៅ:** ជារុក្ខជាតិដែលមានកំពស់ពី១៥-៣០ម ហើយមានអង្កត់ផ្ចិតរហូតដល់លើសពី១០០ ស ម ទៀតផង ។ វាច្រើនដុះលើដីទំនាប និងដីភ្នំ ដែលមានរយៈកំពស់មិនលើស៦០០ម នៃឧបទ្វីបឥណ្ឌូចិន ជាឈើប្រណីតមានពណ៌ក្រហម សំរាប់ ធ្វើជាគ្រឿងសំណង់ និងសង្ហារឹម ។ ផ្លែវាមានរាងមូល និងមានស្លាប មួយស្ទើងព័ទ្ធជុំវិញ ។ ក្នុងផ្លែនីមួយៗជាទូទៅមានគ្រាប់មួយ តែក៏អាចមានគ្រាប់ពីរដែរ ហើយគ្រាប់ទាំងនេះរុំស្រោបដោយសំបកផ្លែដែល ចាកស្រេះគ្នា យ៉ាងមាំដែលអាចជាការរាំងដល់ ដំណុះរបស់ គ្រាប់ ។ គេសង្កេតឃើញផ្លែវាចាប់ផ្តើមទុំនៅចុងខែ តុលា-ធ្នូ ហើយផ្លែនេះអាចស្ថិតនៅ ជាប់នឹងដើមជាយូរខែទៀត ប្រសិនបើវាមិនត្រូវបានគេបេះវាទេនោះ ។

**ខ-បញ្ហាដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការពិសោធន៍:** ចំពោះគ្រាប់ឈើប្រភេទនេះ ទាំងការទុកដាក់ និងការបេះប្រមូលមិនមានបញ្ហាចោទឡើយ តែបញ្ហារបស់វា គឺការធ្វើប្រព្រឹត្តិកម្មគ្រាប់ពូជដែលធ្វើឱ្យគ្រាប់ឆាប់ដុះលូតលាស់ និងទទួលបានអត្រាដំណុះខ្ពស់ ។ ក្នុងការពិភាក្សាជាមួយមន្ត្រីថ្នាលមួយចំនួន បានផ្តល់នូវរបៀបធ្វើប្រព្រឹត្តិកម្មផ្សេងៗគ្នា ហើយអត្រាដំណុះមិនមានការកត់ត្រាច្បាស់លាស់ទៀតផង ជាពិសេសទៅទៀតនោះប្រភេទនេះតែងតែជាទីមិនពេញចិត្តពីសំណាក់អ្នកដាំដុះ ព្រៃឈើ ដោយសារតែការពិបាកក្នុងការធ្វើប្រព្រឹត្តិកម្មគ្រាប់របស់វា និងក៏រិតលូតលាស់របស់វាមានលក្ខណៈយឺត ហើយឈើប្រភេទនេះជាទីពេញនិយមបំផុតសំរាប់ការសាងសង់ និងសង្ហារឹមជាហេតុធ្វើឱ្យស្ថានភាពសុវត្ថិភាពរបស់ប្រភេទនេះកំពុងឋិតក្នុងការគំរាមកំហែង ។ ដើម្បីចូលរួមក្នុងការដោះស្រាយបញ្ហាលំបាកក្នុងការធ្វើប្រព្រឹត្តិកម្ម បន្ទប់ពិសោធន៏គ្រាប់ពូជបានផ្តោតការយកចិត្តទុកដាក់ទៅលើការធ្វើប្រព្រឹត្តិកម្ម និងសិក្សាទៅលើរយៈពេលនៃការទុកដាក់គ្រាប់របស់វា ។

**គ-ការបេះប្រមូល និងការប្រឡេះគ្រាប់:** ដើម្បីជាការពិសោធន៏ យើងបានបេះប្រមូលផ្លែធ្នង់មួយចំនួនយកមកសិក្សាដោយបានធ្វើការកាត់មែកតូចៗរបស់វាដែលមានផ្លែទុំ ហើយទងដែលជាប់នឹងនឹងផ្លែនៅមានពណ៌បៃតងនៅឡើយ ហើយរយើងបានយកមែកទាំងនេះមកប្រឡេះយកផ្លែនៅទីកន្លែងមួយ ។ បន្ទាប់មកផ្លែទាំងនេះ( មិនកាត់ស្លាបចេញទេ) ត្រូវបានខ្ចប់ក្នុងស្បោងក្រណាត់ផាឱបដែលក្នុងមួយស្បោងមានផ្លែទំងន់ប្រហែល ១គ ក្រ ហើយស្បោងផ្លែទាំងនេះត្រូវបានដឹកយកមកបន្ទប់ដោយរថយន្តដោយមានគ្របក្រណាត់ពីលើថែមមួយជាន់ទៀត រួចដឹកមកកានបន្ទប់ពិសេធន៏ ។



រូបទី១-ការកាត់មែក និងប្រឡេះយកផ្លែធ្នង់




រូបទី២-ការវេចខ្ចប់ផ្លែធ្នង់មុននឹងដឹកជញ្ជូន

## ឃ-លទ្ធផលនៃការពិសោធន៍

### ឃ.១-ប្រវត្តិរបស់ផ្លែ:

| | |
|---|---|
| .កាលបរិច្ឆេទនៃការប្រមូល | ២៩ វិច្ឆិកា ២00២ |
| .ទីកន្លែងប្រមូល | បាក់ស្នា ខេត្តកំពង់ធំ |
| .ទំងន់ផ្លែ | ៨៨៣,៥0 ក្រាម ក្នុង ១000 ផ្លែ ឬ ១១៣២ផ្លែ ក្នុង១ គីឡូក្រាម |
| .កំរិតសំណើមដំបូង | ១២,៧៣% |

### ឃ.២-ការធ្វើប្រព្រឹត្តិកម្មគ្រាប់ពូជ:

ក្នុងរយៈពេលនៃការចុះធ្វើការពិភាក្សាជាមួយមន្ត្រីថ្នាល មន្ត្រីមួយចំនួនបានផ្តលជាយោបល់ក្នុងការធ្វើប្រព្រឹត្តិកម្មដោយការត្រាំទឹកក្តៅ មន្ត្រីខ្លះផ្តល់យោបល់ដោយការដុតគ្រាប់ មន្ត្រីខ្លះជូនយោបល់ ដោយការកាត់ស្លាបជុំវិញផ្លែ។ ដោយទទួលបាននូវការចូលរួមវិភាគទានខាងលើ យើងបានធ្វើប្រព្រឹត្តិកម្មគ្រាប់ជា៤របៀប ហើយទទួលបានលទ្ធផលដូចតទៅ:

**លទ្ធផលនៃការធ្វើប្រព្រឹត្តិកម្មតាម៤របៀបផ្សេងគ្នា**

| របៀបធ្វើប្រព្រឹត្តិកម្ម | អត្រាដំណុះ % | រយៈពេលដែលសង្កេតឃើញដំណុះដំបូង |
|---|---|---|
| ១-បណ្តុះត្រួតពិនិត្យ( មិនធ្វើប្រព្រឹត្តកម្ម) | ២៧.៥0% | ៣៨ ថ្ងៃ |
| ២-ត្រាំទឹកក្តៅ៥0°C រួចទុកឱ្យត្រជាក់ រយៈពេល ១យប់ | ៨,៥0% | ៣២ថ្ងៃ |
| ៣-ដុតសំបកផ្លែ រួចត្រាំក្នុងទឹកធម្មតាមួយយប់ | 0,៥0% | ៣៨ថ្ងៃ |
| ៤-ខាត់សំបកផ្លែឱ្យស្តើង រួចត្រាំទឹកធម្មតាមួយយប់ | ៤៥% | ១៧ថ្ងៃ |

**សន្និដ្ឋាន:** ដោយផ្អែកលើលទ្ធផលនៃការពិសោធន៍ខាងលើ យើងឃើញថា ប្រព្រឹត្តិកម្មដោយការខាត់សំបកផ្លែ រួចត្រាំទឹកមួយយប់ គឺជាវិធីដែលល្អបំផុត បើប្រៀបធៀបទៅនឹងការធ្វើប្រព្រឹត្តិម្មដទៃទៀត។ ដូចនេះគ្រាប់ធ្នង់ជាគ្រាប់ដែលមានលក្ខណៈសំងំមេកានិច ដោយសំបកផ្លែបានរាំងខ្ទប់ការរីកដុះដាលរបស់អំប្រ៊ីយ៉ុដែលបានរីកចំរើនបន្ទាប់ពីអំប្រ៊ីយ៉ូនេះបានស្រូបយកជាតិទឹកពីខាងក្រៅ។ ការណ៍នេះនាំឱ្យយើងមានមូលដ្ឋានក្នុងការ ធ្វើប្រព្រឹត្តិកម្មផ្លែធ្នង់ នៅដំណាក់កាលក្រោយៗទៀត។




រូបទី៣-ការដាប់ច្រិបស្លាបជាយខាងផ្លែធ្នង់មុននឹងដាក់ត្រាំទឹក




រូបទី៤-ដំណុះកូនធ្នង់បន្ទាប់ពីធ្វើប្រព្រឹត្តិកម្មរួច

### ឃ-៣-ការថែរក្សាទុកដាក់

យើងបានវេចខ្ចប់ផ្លែធ្នង់ទាំងស្លាបក្នុងស្បោងប្លាស្ទិច ហើយបិទមាត់រួចយកទៅថែរក្សាទុក នៅក្នុងពីរលក្ខខណ្ឌគឺ បន្ទប់ធម្មតា និងទូរត្រជាក់១០°C ។ ក្នុងដំណាក់កាលនេះ ក្នុងការធ្វើប្រព្រឹត្តិកម្ម យើងបានធ្វើការកាត់ជុំវិញផ្លែ ឬដាប់ច្រិបស្លាបផ្លែធ្នង់ ដោយដែកប្រហោង ដោយធ្វើឱ្យជាយសំបកគ្រាប់ដាច់របើកបន្តិច ដើម្បីឱ្យអំប្រិយ៍អាចរិកលូត លាស់បាន តែជៀសវាងមិនឱ្យប៉ះពាល់គ្រាប់ឡើយ រួចដាក់ត្រាំក្នុងទឹកត្រជាក់មួយយប់ទើបដាក់បណ្ដុះ ។

**លទ្ធផលនៃការបណ្ដុះបន្ទាប់ពីការថែរក្សាទុក**

| រយៈពេលនៃការថែរក្សាទុក | លក្ខខណ្ឌនៃការទុកដាក់ | កំរិតសំណើមបន្ទាប់ពីការថែរក្សា | អត្រាដំណុះ |
|---|---|---|---|
| ១ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១២,៤០% | ៤៥,៥០% |
| | ក្នុងបន្ទប់ធម្មតា | ១១,៦៧% | ៥០% |
| ៣ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១០,៩២% | ៥៤% |
| | ក្នុងបន្ទប់ធម្មតា | ១១,១០% | ៥០% |
| ៦ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១០,៥២% | ៤៧% |
| | ក្នុងបន្ទប់ធម្មតា | ១០,៩៨% | ៣៤% |
| ៩ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១០,៩២% | |
| | ក្នុងបន្ទប់ធម្មតា | ១១,៣០ | |

**សន្និដ្ឋានៈ** ការថែរក្សាគ្រាប់ធ្នងមិនទាក់ទងទៅនឹងលក្ខខណ្ឌនៃទីកន្លែងទុកដាក់ឡើយ ។ ទាំងក្នុងទូរដែលមានសីតុណ្ហភាព១០°C និងក្នុងបន្ទប់ធម្មតាសុទ្ធតែផ្ដល់នូវអត្រាដំណុះប្រហាក់ប្រហែលគ្នា ។

**យោបល់ចំពោះការធ្វើលទ្ធកម្មគ្រាប់ធ្នង់ៈ** យើងគួរបេះប្រមូលផ្លែធ្នង់ឱ្យបានទាន់ពេលវេលា ការយឺតយ៉ាវអាចធ្វើឱ្យអត្រាដំណុះចុះទាប ពេលវេលាដែលសមរម្យសំរាប់ការប្រមូលផ្លែធ្នង់គឺ នៅដើមខែវិច្ឆិកា រហូតដល់ខែធ្នូ ហើយលក្ខណៈរបស់ផ្លែទុំគឺស្រាលសំបុរត្នោត និងមានទងនៅពណ៌បៃតងនៅឡើយ ។

ការប្រមូលគួរធ្វើឡើងដោយការកាត់មែកតូចៗដែលមានផ្លែទុំ រួចយកវាមកបេះយកផ្លែនៅខាងក្រោមដើម រួចខ្ចប់វានឹងថង់ក្រណាត់ផាឌិប ដែលអាចមានខ្យល់ចេញចូលបានរួចដឹកមកកាន់ថ្នាលបណ្ដុះដោយមានគ្របក្រណាត់ពីលើមួយជាន់ថែមទៀតផង ដើម្បីការពារការរំហួតនៃសំណើមរបស់ផ្លែ ។ មិនគួររង់ចាំរហូតដល់ផ្លែធ្នង់ជ្រុះទេ ព្រោះផ្លែវាអាចឋិតនៅជាប់នឹងដើមបានយូរពេលថែមទៀត ដែលជាហេតុនាំឱ្យខកខានដល់ការងារដាំដុះ ហើយអាចនឹងបន្ថយនូវអត្រាដំណុះទៀតផង ។

ដោយផ្អែកតាម លទ្ធផលនៃការធ្វើប្រព្រឹត្តិកម្មខាងលើ យើងអាចសន្និដ្ឋានបានថា គ្រាប់ធ្នង់ជាគ្រាប់ដែលមានភាពសំងំនៅត្រង់សំបកផ្លែ ដោយសំបកផ្លែបានរាំងខ្ទប់ការដុះលូតលាស់នៃអំប្រិយ៍ ដូច្នេះដើម្បីបំបែកភាពសំងំរបស់សំបកផ្លែ យើងគួររិះរកវិធីផ្សេងៗដើម្បីបន្ថយ ឬបំបាត់ភាពរឹងមាំនៃសំបកគ្រាប់ ។ នៅបន្ទប់ពិសោធន៍របស់គំរោងគ្រាប់ពូជឈើកម្ពុជា ការធ្វើប្រព្រឹត្តិកម្ម

បានធ្វើឡើងដោយប្រើដែកប្រហោងដាប់ច្រិបជុំវិញគែមខាងនៃសំបកគ្រាប់ឱ្យហើបបន្តិចរួចដាក់ត្រាំទឹក១យប់ មុននឹងដាក់សាបវាទៅលើដីខ្សាច់ ។ យើងអាចធ្វើការសាបគ្រាប់ផ្ទង់ដោយមិនបាច់ធ្វើប្រព្រឹត្តិកម្មក៏បាន តែ ដំណុះរបស់វាអាចអូសបន្លាយពេលវេលាយូរ រហើយអត្រាដំណុះអាចទាបជាង ។

ក្នុងការថែរក្សាទុកដាក់ យើងអាចទុកដាក់វាទាំងស្លាបក៏បាន តែដើម្បីបន្ថយនូវភាពសំពីងសំពោងរបស់ស្លាប យើងគួរកាត់ក្រឡឹងស្លាបដែលនៅជុំវិញផ្លែចេញ តែត្រូវមានការប្រយ័ត្នកុំឱ្យប៉ះទង្គិចដល់គ្រាប់ដែលនៅខាងក្នុង ។ រីឯរយៈពេល និងលក្ខខណ្ឌនៃការទុកដាក់ មិនចោទជាបញ្ហាធ្ងន់ធ្ងរពេកទេចំពោះផ្លែប្រភេទនេះ តែការណ៍ដែលគួរយកចិត្តទុកដាក់នោះគឺ ត្រូវវេចខ្ចប់ផ្លែឱ្យបានត្រឹមត្រូវមុននឹងធ្វើការទុកដាក់ ដោយច្រកផ្លែទាំងនេះក្នុងបាវ ឬសំភារៈផ្ទុកដ៏ទៃទៀតឱ្យបានជិតល្អ ហើយទុកវាក្នុងម្លប់ ជៀសវាងធ្វើការទុកដាក់ដោយមិនមានការវេចខ្ចប់ត្រឹមត្រូវ និងទុកចោលនៅទីវាលក្រោមគំដៅថ្ងៃ និងហាលខ្យល់ ។

**២ -ប្រភេទនាងនួន:** (*Dalbergia bariensis*)

**ក-លក្ខណៈទូទៅ:** ជារុក្ខជាតិធំ មានកំពស់ពី ១៥ម-៣០ម អង្កត់ផ្ចិតជាទូទៅមានពី៤០ សម រហូតដល់ ៨០ សម ឬអាចលើសពីនេះទៀតផង ។ ជារុក្ខជាតិដែលគេឃើញមានដុះតែក្នុងតំបន់ព្រៃត្រូពិច ។ នៅប្រទេសកម្ពុជា គេសង្កេតឃើញច្រើនមានដុះក្នុងព្រៃនៃតំបន់ខ្ពង់រាបភាគឥសាន្តនៃប្រទេសក្នុង ខេត្តព្រះវិហារ ស្ទឹងត្រែង រតនគីរី .....ដោយឡែកនៅបណ្តាខេត្តផ្សេងទៀតក៏ឃើញមានដុះដែរ តែរបាយដំណុះមានតិចជាង ។ សាច់ឈើមានបណ្តូលខ្លឹមក្រាស់ និងមានពិណក្រម៉ៅ ឯសាច់ស្រាយវា (សាច់ខាងមិនមានខ្លឹម) មានពិណលឿងប្រលែត ។ ជាឈើដែលពេញនិយមណាសក្នុងការធ្វើជាគ្រឿងសង្ហារឹម និងសំណង់ ហើយសាច់ឈើប្រើយូរ កាន់តែរលោងល្អ ។








**រូបទី៦**-ដំណុះកូននាងនួនក្នុងព្រៃធម្មជាតិ **រូបទី៧**-ផ្លែនិងស្លឹកនាងនួនដែលនៅខ្ចី **រូបទី៨**-ផ្លែ និងគ្រាប់នាងនួនពេលទុំ

**ខ-លក្ខណៈផ្លែ និងគ្រាប់:** ផ្លែនាងនួនជាប្រភេទផ្លែស្ងួត មិនប្រេះ មានពណ៌បៃតងខ្ចីនៅពេលខ្ចី និងប្រែជាពណ៌ត្នោតចាស់នៅពេលទុំ ហើយក្នុងផ្លែនីមួយភាគច្រើនមានគ្រាប់តែមួយ តែក៏មានផ្លែមួយចំនួនក៏មានគ្រាប់ពីរដែរ គេកំរឃើញផ្លែរបស់វាមួយមានគ្រាប់បី ឬលើលពីនេះណាស់ ។ គ្រាប់របស់វា មានទំហំតូចល្មម ប្រហែលនឹងគ្រាប់អំពិលទឹក តែវាមានពណ៌ត្នោតចាស់

ជារឿយៗ គ្រាប់ដែល ទទួលបានពីដើមមេខុសគ្នា ច្រើនតែមានទំហំ និងពណ៌ខុសគ្នាបន្តិចបន្តួចគឺមិនដូចគ្នាសុទ្ធសាធទេ ។

ផ្លែវាចាប់ផ្ដើមទុំនៅខែ វិច្ឆិកានៃឆ្នាំចាស់ រហូតដល់ខែមករានៃឆ្នាំបន្ទាប់ ។ ផ្លែ និងគ្រាប់នៅពេលទុំតែងរងនូវការបំផ្លាញអំពីសត្វល្អិតយ៉ាងខ្លាំង ។

**គ-បញ្ហាដែលត្រូវផ្ដោតការយកចិត្តទុកដាក់ក្នុងការពិសោធន៍:** ជាប្រភេទដែលកំពុងរងទទួលនូវការគំរាមកំហែងយ៉ាងខ្លាំង ហើយត្រូវបានអង្គការIUCN ធ្វើចំណាត់ថ្នាក់ជាប្រភេទដែលឈានទៅរកការផុតពូជ (ពិន្ទុសុវត្ថិភាព=៥) ។ រីឯការធ្វើលទ្ធកម្មរបស់គ្រាប់វា ក៏នៅមិនទាន់ច្បាស់លាស់ ទាំងពេលវេលា និងការបេះប្រមូល ការប្រឡេះគ្រាប់ ការធ្វើប្រព្រឹត្តិកម្មគ្រាប់ ការថែរក្សាទុកដាក់.... ។

**ឃ-ការបេះប្រមូល និងការប្រឡេះគ្រាប់:** ដើម្បីជាការពិសោធន៍ យើងបានបេះប្រមូលផ្លែនាងនួនដោយឡើងលើដើម ហើយកាត់មែកតូចៗដែលមានផ្លែទុំ យកមកបេះយកផ្លែនៅខាងក្រោមដើម ។ ផ្លែដែលបានបេះប្រមូលរួចហើយ ត្រូវបានយកទៅហាលថ្ងៃដើម្បីសំងួតមុននឹងវេចខ្ចប់វានៅក្នុងស្បោងក្រណាត់ផាឌិប រួចដឹកជញ្ជូនវាមកកាន់បន្ទប់ពិសោធន៍ ។

នៅបន្ទប់ពិសោធន៍ យើងបានហាលផ្លែនាងនួនបន្ថែមទៀតរហូតដល់សំបកផ្លែវាស្ងួត និងស្រួយល្មម រួចយកទៅបុកនឹងត្បាល់បុកបបន្ថើរៗ កុំឱ្យបែកគ្រាប់ រួចរោយ ឬអុំវា ដើម្បីបង្ហើរសំបកគ្រាប់ចេញ និងរើសប្រមូលយកគ្រាប់ដែលបែកចេញពីផ្លែ ។ ចំពោះផ្លែណាដែលមិនទាន់បែក យើងយកវាមកបុកបន្តទៀតរហូតដល់ផ្លែទាំងនោះបែក ចេញគ្រាប់ទាំងអស់ ។

បន្ទាប់ពីប្រឡេះយកគ្រាប់រួចហើយ យើងយកគ្រាប់ទាំងនេះទៅដាក់ក្នុងទឹក ដើម្បីបណ្ដែតយកគ្រាប់ស្អុយ និងគ្រាប់ដែលបានបំផ្លាញដោយសត្វល្អិតចេញ រួចយកគ្រាប់ដែលល្អយកទៅហាលថ្ងៃម្ដងទៀតរហូតដល់គ្រាប់ស្ងួតល្មម ទើបចាប់ផ្ដើមពិសោធន៍ និងធ្វើការថែរក្សាទុកដាក់ ។



រូបទី៩-ការឡើងបេះផ្លែនាងនួន



រូបទី១០-ការហាលគ្រាប់នាងនួនមុននឹងប្រឡេះ



រូបទី១១-ការបុកប្រឡេះគ្រាប់នាងនួន

**ង-លទ្ធផលនៃការពិសោធន៍:**

**ង-១-ប្រវត្តិរបស់គ្រាប់:**

.កាលបរិច្ឆេទនៃការប្រមូល: ២១ វិច្ឆិកា ២០០២

.ទីកន្លែងប្រមូលៈ ភូមិប៉ាលហាល ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

.ទំងន់គ្រាប់ៈ ១៦៣ ក្រាម ក្នុង១០០០គ្រាប់ ឬ ៦១៣៥គ្រាប់ ក្នុង ១ គីឡូក្រាម

.កំរិតសំណើមដំបូងមុនពេលថែរក្សាៈ ១៤,២៩%

.ការកាត់គ្រាប់ពិនិត្យៈ ៨៩%

**ង-២-ការធ្វើប្រព្រឹត្តិកម្មគ្រាប់ៈ**

ដើម្បីស្វែងយល់នូវរបៀបធ្វើប្រព្រឹត្តកម្មដែលសមស្របបំផុត សំរាប់គ្រាប់នាងនួន់ យើងបានធ្វើប្រព្រឹត្តកម្មគ្រាប់ពូជតាម ៤ របៀបផ្សេងគ្នា ហើយទទួលបានលទ្ធផលដូចតទៅៈ

**លទ្ធផលនៃការធ្វើប្រព្រឹត្តិកម្មតាម ៤ របៀបផ្សេងគ្នា**

| របៀបធ្វើប្រព្រឹត្តិកម្ម | អត្រាដំណុះ % | រយៈពេលដែលសង្កេតឃើញដំណុះដំបូង |
|---|---|---|
| ១-បណ្តុះត្រួតពិនិត្យ ( មិនធ្វើប្រព្រិត្តិកម្ម) | ៥៥% | ៧ថ្ងៃ ឃើញមានដំណុះ២២,៥០% |
| ២-ត្រាំទឹក ៤០°C រួចទុកចោលមួយយប់ | ៦៤% | ៧ថ្ងៃ ឃើញមានដំណុះ២២,៥០% |
| ៣-ត្រាំទឹកធម្មតាមួយយប់ | ៥០% | ៧ថ្ងៃ ឃើញមានដំណុះ៣១,៥០% |
| ៤-ដុតសំបកគ្រាប់ដោយដែកអគ្គិសនី | ១០% | ៧ថ្ងៃ ឃើញមានដំណុះ ៧% |

**សន្និដ្ឋានៈ**ដោយពិនិត្យលើលទ្ធផលដែលទទួលបានខាងលើ យើងឃើញថា ការធ្វើប្រព្រឹត្តិកម្មទី ១,ទី២,និងទី៣ គឺទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នា ដូចនេះគ្រាប់នាងនួនមិនមានលក្ខណៈសំងំទេ ឬមានលក្ខណៈសំងំរូបតិចបំផុត ( ផ្អែកលើការធ្វើប្រព្រឹត្តិកម្មទី២) ។ ដូចនេះវិធីមួយយក្នុងបណ្តាវិធីទាំងបីអាចយកមកអនុវត្ត សំរាប់ការបណ្តុះគ្រាប់នាងនួនបានដូចគ្នា ។

**ង.៣-ការថែរក្សាទុកដាក់**

បន្ទាប់ពីការពិសោធន៏នេះ យើងបានយកគ្រាប់នាងនួន ទៅវេចខ្ចប់នឹងស្បោងប្លាស្ទិច រួចយកទៅថែរក្សាទុកនៅទីកន្លែងដែលមានសីតុណ្ហភាពខុសគ្នាគឺៈ បន្ទប់ធម្មតា និងទូរដែលមានសីតុណ្ហភាព១០°C ។ នៅក្នុងបន្ទប់ពិសោធន៏ យើងបានជ្រើសរើសយកវិធីទី២ យកមកធ្វើប្រព្រឹត្តិកម្មគ្រាប់សំរាប់ការពិសោធន៏ក្រោយៗទៀត ។ នៅរយៈពេលកំណត់ យើងបានយកគ្រាប់មកបណ្តុះ ហើយទទួលបានលទ្ធផលៈ

**លទ្ធផលនៃការបណ្តុះគ្រាប់នាងនួនបន្ទាប់ពីការថែរក្សាទុក**

| រយៈពេលនៃការថែរក្សាទុក | លក្ខខណ្ឌនៃការទុកដាក់ | កំរិតសំណើមបន្ទាប់ពីការថែរក្សា | អត្រាដំណុះ |
|---|---|---|---|
| ១ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១៤,១៧% | ៦៤,៥០% |
| | ក្នុងបន្ទប់ធម្មតា | ១៤,៩៩% | ៦០% |
| ៣ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១៣,៥៩% | ៦១% |

| | | | |
|---|---|---|---|
| | ក្នុងបន្ទប់ធម្មតា | ១៣,៥៨% | ៣៦% |
| ៦ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១៣,៤៧% | ៥០% |
| | ក្នុងបន្ទប់ធម្មតា | ១៣,២០% | ៧% |
| ៩ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ១៣,៣៦% | |
| | ក្នុងបន្ទប់ធម្មតា | ១៣,២១% | |

**សន្និដ្ឋានៈ** ការថែរក្សាគ្រាប់នាងនួនក្នុងទូរដែលមានសីតុណ្ហភាព១០°C ទទួលបានលទ្ធផលល្អជាងការថែរក្សាក្នុងបន្ទប់ធម្មតា ។

**យោបល់ចំពោះការធ្វើលទ្ធកម្មគ្រាប់នាងនួនៈ** យើងគួរប្រមូលគ្រាប់នាងនួនឱ្យបានទាន់ពេលវេលា ព្រោះថាការយឺតយ៉ាវវានឹងធ្វើឱ្យផ្លែ និងគ្រាប់រងនូវការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីសត្វល្អិត ហើយអាចនឹងនាំឱ្យខូចខាតទាំងស្រុងទៀតផង ប្រសិនបើយើងនៅតែបន្តការយឺតយ៉ាវនេះយូរតទៅទៀត ។ យើងមិនគួររង់ចាំឱ្យផ្លែនាងនួនជ្រុះមកដីទេ ។ ក្នុងការប្រមូល យើងគួរឡើងលើដើម រួចកាត់មែកតូចៗដែលមានផ្លែទុំ យកមកបេះយកផ្លែ រួចហើយផ្លែដែលបេះបាន គួរហាលឱ្យស្ងួតល្អមុននឹងដឹកជញ្ជូនមកកាន់ថ្នាល ឬទីកន្លែងគោលដៅផ្សេងទៀត ។ ប្រសិនបើយើងមិនបានហាលវាឱ្យស្ងួតល្អទេ ផ្លែទាំងអស់នោះអាចនឹងខូចដោយសារការរាត ត្បាតនៃផ្សិតចង្រៃ ដែលបណ្តាលមកពីសំណើមរបស់ផ្លែ ដែលមិនបានហាលស្ងួតល្អ ។

នៅមុនពេលប្រឡេះ ផ្លែគួរតែហាលឱ្យស្ងួតបន្ថែមទៀត ដេធីម្បីឱ្យសំបកផ្លែស្រួយងាយស្រួលក្នុងការបុកបំបែករយកគ្រាប់ចេញ ។ ផ្លែដែលហាលស្ងួតហើយ គួរយកទៅបុកនឹងត្បាល់បុកដោយបន្ថើរៗ ត្រូវជៀសវាងកុំបុកផ្លែវាខ្លាំងៗពេក ព្រោះវាអាចនាំ ឱ្យបែក និងខូចគ្រាប់ ។ បន្ទាប់ពីបុករួចហើយ ផ្លែ និងគ្រាប់ដែលបុកបាន យើងអាចយកវាមកអុំ ឬរោយយកកំទេចកំទីសំបកគ្រាប់ដែលបែកចេញ ហើយផ្លែដែលមិនទាន់បែកចេញគ្រាប់ យើងត្រូវដាក់វាបុកសាជាថ្មីម្តងទៀតរហូតដល់ផ្លែត្រូវបែកគ្រាប់ចេញមក រួចអុំ ឬរោយវាសំអាត ។

បន្ទាប់ពីប្រឡេះបានគ្រាប់រួចហើយ  គ្រាប់នេះក៏គួរតែហាលបន្ថែមទៀតដើម្បីឱ្យស្ងួតល្អ (គួរហាលក្នុងមួយរយៈពេលប្រហែលមួយថ្ងៃ) មុននឹងធ្វើការទុកដាក់ ។ ក្នុងករណី ដែលគ្រាប់សង្កេតឃើញមានការរាតត្បាតដោយសត្វល្អិត ឬមានពងសត្វនៅជាប់នឹងគ្រាប់ យើងត្រូវរើសយកគ្រាប់ទាំងនេះចេញ ព្រោះថាសត្វល្អិតដែលនៅជាប់នឹងគ្រាប់ទាំងនេះ វាអាចនឹងពង្រីកការរាតត្បាតរបស់វាតទៅទៀតរហូតដល់គ្រាប់ទាំងអស់ដែលនៅក្នុងស្បោងរបស់យើងត្រូវវាបំផ្លាញទាំងអស់ ។ ប្រសិនបើសង្កេតឃើញមានគ្រាប់ច្រើនត្រូវសត្វល្អិតបំផ្លាញនោះ ហើយយើងមិនអាចនឹងរើសចេញអស់ នោះគួរចាក់គ្រាប់ទាំងអស់ចូលទៅក្នុងធុងទឹកមួយ រួចស្រង់យកគ្រាប់ដែលអណ្តែតចេញ ទុកតែគ្រាប់ដែលលិចចុះប៉ុណ្ណោះ ។ តែទោះជាយ៉ាងណាក៏ដោយ ក្នុងករណីនេះក៏គ្រាប់ដែលលិចអាចនឹងនៅសល់ ឬនៅមានគ្រាប់ដែលមានសត្វល្អិតតោង ឬមានភ្ជាប់ដោយពងសត្វល្អិតដែរ ដូចនេះបន្ទាប់ពីត្រាំរួច យើងត្រូវហាលវាឱ្យស្ងួត រួចយកវាមកពិនិត្យ និងរើសវាចេញឱ្យបានហ្មត់ចត់ មិនត្រូវឱ្យវាមាននៅសល់ក្នុងស្បោងពូជឡើយ

មុននឹងធ្វើការទុកដាក់វា ។ យើងអាចដាក់ថ្នាំសំលាប់សត្វល្អិតច្របល់ជាមួយនឹងគ្រាប់បាន ដើម្បីថែរក្សា និងការពារវាពីការបំផ្លាញរបស់សត្វល្អិត តែត្រូវប្រាកដថា ថ្នាំដែលយើងប្រើនោះមិនប៉ះពាលដល់គ្រាប់ ឬបំផ្លាញគ្រាប់ឡើយ ។

ប្រសិនបើគ្រាប់មិនមានការបំផ្លាញដោយសត្វល្អិតទេនោះ គ្រាប់ដែលបានប្រឡេះ និងហាលត្រឹមត្រូវហើយ គួរទុកដាក់ក្នុងស្បោងផ្លាស្ទិចបិទមាត់ ឱ្យជិតល្អ រួចថែរក្សាវាទុកក្នុងទូរដែលមានសីតុណ្ហភាពទាប ( ប្រហែល១០°C ) ក្នុងករណីនេះ យើងអាចថែរក្សាវាបានរយៈពេលលើសពី ៩ខែ ( ពិនិត្យលទ្ធផលពិសោធន៍ខាងលើ ) ។ ប្រសិនបើ មិនមានទូរសំរាប់ថែរក្សា ដែលមានសីតុណ្ហភាពអាចតំរូវបានដូចខាងលើទេនោះ គ្រាប់នាងនួនដែលប្រឡេះ សំអាត និងហាលបានល្អហើយនោះ គួរវេចខ្ចប់វានៅក្នុងស្បោងប្លាស្ទិចបទេជិត រួចទុកវានៅក្នុងម្លប់ ឬក្នុងបន្ទប់ដែលមានខ្យល់ចេញចូលល្អ តែទោះជាយ៉ាងណាក៏ដោយ ក៏លទ្ធផលនៃការពិសោធន៍ខាងលើ បង្ហាញថា ការថែរក្សាទុកដាក់បែបនេះ មិនអាចអូសបន្លាយការរស់នៅរបស់គ្រាប់នាងនួនឱ្យបានលើសពី១ខែឡើយ ។ ដូចនេះការទុកដាក់គ្រាប់នាងនួនក្នុងមជ្ឈដ្ឋានដែលមានសីតុណ្ហភាពទាប គឺជាការចាំបាច់ដែលគួរតែអនុវត្តនៅក្នុងការថែរក្សានិងទុកដាក់គ្រាប់នាងនួន ។

**៣-ប្រភេទស្ដៅ** (*Azadirachta indica*)

**ក-លក្ខណៈទូទៅ:** ស្ដៅជារុក្ខជាតិដែលមានកំពស់ពី ៤-៦ម ឬលើសពីនេះ ។វាច្រើនដុះនៅទីវាល ឬព្រៃស្រោង ។ គួដើមជាធម្មតាខ្លី ហើយបែកមែកនៅកំពសមិនលើសពី៧,៥ម រីឯអង្កត់ផ្ចិតអាចមានទំហំរហូតដល់ ៩០ សម ហើយតួដើមជួនកាលមានរាងមិនមូលល្អទេ ។ ស្ដៅត្រូវបានគេនិយមដាំនៅស្ទើរតែពាសពេញសាកលលោក ។ នៅប្រទេសកម្ពុជា គេនិយមដាំវាដើម្បីយកស្លឹក និងផ្កាសំរាបបរិភោគ ហើយដើមវា សំរាប់ប្រើប្រាស់ជាគ្រឿងសំណង់ទូទៅ ។ ស្លឹកមានរាងមូលស្រួចដូចផ្លែលំពែង ខ្លះទៀតមានរាងមូលទ្រវែង ។ ផ្កាវាមានពណ៌ស ផ្លែវាមានរាងមូលទ្រវែង រលោង និងមានពណ៌បៃតង នៅពេលខ្ចី និងប្រែជាពណ៌លឿងស្រស់នៅពេលទុំ ហើយមានសាច់ដែលមានជាតិស្អិតរុំស្រោបព័ទ្ធជុំវិញគ្រាប់ ។ ផ្លែវាទុំនៅចុងខែមេសា ដល់ ដើមខែមិថុនា ។ សាច់ឈើវាមានដង់ស៊ីតេពី៧២០-៩៣០ គ ក្រ ក្នុងមួយម៉ែត្រគូប ( 720-930 kg/m$^3$ ) នៅក្នុងសំណើម១២% ។





រូបទី១២-ផ្លែ និងស្លឹកស្ដៅ

រូបទី១៣- ផ្លែ និងគ្រាប់ស្ដៅ

**ខ-បញ្ហាដែលនាំឱ្យមានការយកចិត្តទុកដាក់ក្នុងការពិសោធន៍:** ជាប្រភេទឈើ ដែលមានសក្ដានុពលក្នុងការប្រើប្រាស់ទាំងនៅក្នុង និងក្រៅប្រទេស ។ លក្ខណៈសរីរៈរបស់គ្រាប់វា ត្រូវបានគេរាយការណ៍ថា មានលក្ខណៈខុសប្លែកគ្នាទៅតាមតំបន់ ដោយនៅបណ្ដាប្រទេសនានានៅទ្វីបអាស៊ី អ្នកជំនាញគ្រាប់ពូជបានអះអាងថា ជាគ្រាប់ដែលមិនអាចទុកបានយូរ (Recalcitrant) តែនៅបណ្ដាប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិក ត្រូវបានឯកសារមួយចំនួនអះអាងថា ជាគ្រាប់ដែលអាចទុកដាក់ និងថែរក្សាបាន

យូរ ( Orthodox) ។ដោយឡែកនៅប្រទេសកម្ពុជា ពុំទាន់មានឯកសារណាមួយពោលបញ្ជាក់អះអាងអំពីលក្ខណៈសិរិៈ របស់គ្រាប់វានៅឡើយទេ ដែលជាហេតុទាមទារឱ្យមានការពិសោធន៍សាកល្បងមួយឡើង ដើម្បីបញ្ជាក់អំពីបញ្ហានេះ ។

**គ-ការដេះប្រមូល និងការប្រឡេះគ្រាប់:** ជាទូទៅ នៅពេលទុំវាតែងជ្រុះពង្រាយមកដី តែទន្ទឹមនឹងនោះផ្លែវាក៏ជាទីចូលចិត្តរបស់សត្វស្លាបមួយចំនួន ដែលតែងតែចឹកស៊ី ហើយពាំផ្លែ និងគ្រាប់ទៅកាន់ទីកន្លែងផ្សេងៗទៀត ដែលការណ៍នេះហើយជាការដុះពង្រាយនៃប្រភេទនេះដោយធម្មជាតិ ទៅកាន់ទីកន្លែងដទៃទៀត ដែលឆ្ងាយពីដើមមេរបស់វា ។ ដូចនេះការរង់ចាំឱ្យផ្លែស្តៅជ្រុះមក ជាការមួយមិនសូវទទួលបានផលល្អទេ ក្នុងការប្រមូលផ្លែពួកនេះ ។

ដើម្បីជាការពិសោធន៍ យើងបានឡើងលើដើម ហើយកាត់មែកតូចៗដែលមានផ្លែទុំ យកមកបេះយកផ្លែនៅក្រោមដើម រួចប្រមូលវាដាក់ក្នុងស្បោងក្រណាត់ ក្នុងមួយស្បោងប្រហែល ១-២ គ ក្រ រួចដឹកជញ្ជូនមកបន្ទប់ពិសោធន៍ ។

នៅក្នុងបន្ទប់ពិសោធន៍ យើងបានរូតរះចាក់ផ្លែទាំងនេះចូលក្នុងធុងទឹកមួយ រួចច្របាច់វាដោយដៃ ដើម្បីជំរះយកសាច់ផ្លែដែលស្អិតចេញ រួចសិតទឹកដែលមានជាតិសាច់នេះចេញ ហើយស្រង់យកតែគ្រាប់ដែលប្រឡេះបាន ។ ចំពោះផ្លែដែលមិនទាន់របូតគ្រាប់ចេញមក យេកីងបានបន្តច្របាច់វាសាជាថ្មីម្តងហើយ ម្តងទៀតរហូតទាល់តែសព្វផ្លែទុំទាំងអស់ត្រូវបានប្រឡេះយកគ្រាបចេញ ។ គ្រាប់ដែលប្រឡេះ ចេញពីផ្លែហើយ យើងលាងសំអាតវាជាច្រើនលើកច្រើនសារ ដើម្បីជំរះជាតិរំអិល របស់សាច់ផ្លែដែលនៅជុំវិញគ្រាប់ រួចដាក់វាហាលថ្ងៃឱ្យស្ងួតរួចទើបចាប់ផ្តើមធ្វើការពិសោធន៍ និងថែរក្សាទុកដាក់ ។



រូបទី១៤-ការត្រាំ និងច្របាច់ផ្លែស្តៅដើម្បីយកគ្រាប់



រូបទី១៥-ដំណុះកូនស្តៅ ពេលពិសោធន៍

**ឃ-ការពិសោធន៍:**

**ឃ.១-ប្រវត្តិរបស់គ្រាប់:**

| | |
|---|---|
| .កាលបរិច្ឆេទនៃការប្រមូលៈ | ៣០ មេសា ២០០៣ |
| .ទីកន្លែងប្រមូលផ្លែ: | ភូមិធម្មនាថ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ |
| .សំណើមរបស់ផ្លែ: | ៦៨,៧១% |
| .ទំងន់ផ្លែ: | ៣០៧៨ ក្រ ក្នុង ១០០០ គ្រាប់ ឬ ៣២៥ផ្លែ ក្នុង១ គក្រ |
| .សំណើមគ្រាប់បន្ទាប់ពីសំងួតរួចៈ | ៣៨,៦៨% |

- ទំងន់គ្រាប់បន្ទាប់ពីសំងួតរួចៈ ៤៤៤,៥០ក្រ ក្នុង១០០០ គ្រាប់ ឬ ២២៥០គ្រាប់ ក្នុង១គីឡូក្រាម
- ការកាត់គ្រាប់ពិនិត្យៈ ៩១%

## ឃ.២-លទ្ធផលនៃការពិសោធន៍ដំបូង

| កាលបរិច្ឆេទនៃការពិសោធន៍ | ការធ្វើប្រព្រឹត្តិកម្ម | អត្រាដំណុះ % | រយៈពេលឃើញមានដំណុះដំបូង |
|---|---|---|---|
| ០៨ ខែឧសភា២០០៣ | ត្រាំទឹកធម្មតាមួយយប់ | ៨២% | ៧ថ្ងៃ មានដំណុះ ៦៩,៥០% |

**សន្និដ្ឋានៈ** គ្រាប់ស្ពៅមិនមានលក្ខណៈសំងំទេ ដោយការធ្វើប្រព្រឹត្តិកម្មមិនចោទជាបញ្ហាឡើយ ។

### ឃ.៣-ការថែរក្សាទុកដាក់ៈ

នៅក្នុងការថែរក្សទុកដាក់ យើងបែងចែកគ្រាប់ទាំងនេះជាពីរផ្នែក រួចធ្វើការស្តុកទុកនៅទីកន្លែងពីរខុសគ្នា :បន្ទប់ធម្មតា និងទូរដែលមានសីតុណ្ហភាព១០°C ។ រីឯលទ្ធផលនៃការថែរក្សាទុកដាក់ ទទួលបានដូចតទៅៈ

**លទ្ធផលនៃការបណ្តុះគ្រាប់ស្ពៅបន្ទាប់ពីការថែរក្សាទុកដាក់**

| រយៈពេលនៃការថែរក្សាទុក | លក្ខខណ្ឌនៃការទុកដាក់ | កំរិតសំណើមបន្ទាប់ពីការថែរក្សា | អត្រាដំណុះ |
|---|---|---|---|
| ២ អាទិត្យ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ៣៨,៧៣% | ៥៦% |
| | ក្នុងបន្ទប់ធម្មតា | ៤០,៥២% | ៧,៥០% |
| ១ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ៤១,៩២% | ១៩,៥% |
| | ក្នុងបន្ទប់ធម្មតា | ៤៣,០៣% | ០% |
| ៣ ខែ | ក្នុងទូរដែលមានសីតុណ្ហភាព១០°C | ៤០,៥១% | ០% |
| | ក្នុងបន្ទប់ធម្មតា | ៣៩,៦២% | ០% |

**សន្និដ្ឋានៈ** គ្រាប់ស្ពៅមិនអាចថែរក្សាទុកដាក់បានយូរឡើយ ។

**យោបល់ចំពោះការធ្វើលទ្ធកម្មគ្រាប់ស្ពៅៈ** ថ្វីត្បិតតែគ្រាប់ស្ពៅមិនមានការលំបាកក្នុងការធ្វើប្រព្រឹត្តិកម្ម ក៏ដោយ ក៏ការធ្វើលទ្ធកម្មគ្រាប់ស្ពៅចាំបាច់ត្រូវមានការយល់ដឹងឱ្យបានគ្រប់គ្រាន់ដែរ ។ ការធ្វើលទ្ធកម្មគ្រាប់ស្ពៅគួរតែធ្វើឱ្យបានលឿន ដើម្បីទទួលបានគ្រាប់ដែលមានគុណភាពល្អ ។នៅរដូវផ្លែទុំ យើងគួរប្រមូលផ្លែចវាឱ្យបានទាន់ពេល ព្រោះថាបើយើងយឺត យ៉ាវ សត្វអាចនឹងចឹកស៊ីផ្លែរបស់វាអស់ ។ ការប្រមូលគួរតែធ្វើឡើងដោយការកាត់មែកតូចៗដែលមានផ្លែទុំ រួចបេះយកផ្លែ វាច្រកចូលក្នុងស្បោង

ដែលមានខ្យល់ចេញចូលល្អ គួរជៀសវាងដាក់វាក្នុងស្បោងដែលហប់បិទជិត ព្រោះវានាំឱ្យសាច់ផ្លែឆាប់រលួយ និងឡើងមេ ជាហេតុនាំឱ្យគ្រាប់ឆាប់ខូច ។

បន្ទាប់ពីប្រមូលបានហើយ ផ្លែទាងនេះត្រូវរូតរះលាងសំអាតយកសាច់ផ្លែចេញឱ្យបានឆាប់បំផុត តាមការដែលអាចធ្វើទៅបាន ការយឺតយ៉ាវនាំឱ្យផ្លែទាំងនេះឡើងមេ ហើយក្លាយជាអាស៊ីត ដែលបំផ្លាញគ្រាប់ ។ ការលាងសំអាតនេះ ប្រសិនបើអាចធ្វើទៅបាន គួរធ្វើនៅទីកន្លែងដែលមានទឹកហូរ ព្រោះវាងាយស្រួលក្នុងការជំរះយកសាច់ផ្លែចេញបានល្អ ។ ប្រសិនបើពុំមានទឹទឹកហូរ ទេនោះ យើងគួរលាងសំអាតវាក្នុងធុង ឬចានដែក ឬជ័រដែលមានទំហំធំ ហើយសរិតទឹកដែលមានជាតិសាច់ចេញ ។ ធ្វើរបៀបនេះឱ្យបានច្រើនសារ ដើម្បីឱ្យវាជ្រះល្អ ប្រសិនបើយើងលាងវាមិនបានជ្រះល្អទេ នោះគ្រាប់នឹងនៅមានជាប់ជាតិសាច់ដែលសើមជានិច្ច ដែលជាការងាយស្រួលបំផុតសំរាប់ការរាតត្បាតរបស់ផ្សិតចង្រៃ ក្នុងការបំផ្លាញគ្រាប់ ។

បន្ទាប់ពីលាងសំអាតបានត្រឹមត្រូវល្អហើយ គ្រាប់ទាំងនេះត្រូវរូតរះយកវាទៅសាបនៅក្នុងថ្នាលភ្លាមតាមការណ៍ ដែលអាចធ្វើទៅបាន ។

ក្នុងករណីដែលគ្រាប់មិនអាចយកទៅសាបបានភ្លាម យើងគួរដាក់ហាលសំដិលឱ្យបានឆាប់ ។ បន្ទាប់ពីគ្រាប់ស្ងួតល្មមសមរម្យហើយ គួរយកវាទៅដាក់សាបក្នុងថ្នាលឱ្យបានឆាប់ ប្រសិនបើគ្មានការចាំបាច់ណាមួយក្នុងការថែរក្សាទេនោះ ។

មិនគួរថែរក្សាគ្រាប់ស្តៅទុកឡើយ ។ក្នុងករណិដែលគ្រាប់ស្តៅ មិនទាន់អាចយកទៅសាបនៅថ្នាលបានភ្លាមទេនោះ យើងគួរវេចខ្ចប់វាក្នុងស្បោងប្លាស្ទិចឱ្យបានជិត រួចយកទៅរក្សាទុកក្នុងទូរដែលមានសីតុណ្ហភាពប្រហែល១០°C តែការថែរក្សាបែបនេះមិនគួរឱ្យលើសពី ២អាទិត្យទេ (ពិនិត្យមើលតារាងនៃការថែរក្សាទុកដាក់ខាងលើ) ។

**៤-ប្រភេទពពេល** (*Shorea roxburxhii* G.Don)

**ក-លក្ខណៈទូទៅ:** ជារុក្ខជាតិធំ អាចមានកំពស់រហូតដល់៣០ម ។ គេសង្កេតឃើញវាដុះនៅព្រៃល្បោះ និងព្រៃស្រោងនៃឧបទ្វីបឥណ្ឌូចិន ម៉ាឡេស៊ី និងឆ្នេរសមុទ្រខាងកើតនៃញប្រទេសឥណ្ឌា ។ ផ្លែវាមានស្លាប៥ ដែលក្នុងនោះ ៣មានទំហំមធ្យម និង២ទៀត តូច និងមិនសូវច្បាស់ ។ ផ្លែទុំនៅខែ មេសា ឧសភា ។ ពេលទុំ ស្លាបវាមានសភាពស្ងួត ផ្លែវាមានសំបុរត្នោតចាស់ និងរលោង ។ គេនិយមយកសំបកវាទៅត្រាំទឹកត្នោតដើម្បីឱ្យទឹកត្នោតថ្លាល្អ មិនជូរ ។ សាច់ឈើមានពណ៌លឿងភ្លាវ ច្រើនប្រើសំរាប់ការសាងសង់នាវា ។



**រូបទី១៦**-ដើមនិងផ្លែពពេល



**រូបទី១៧**-ផ្លែពពេលទុំ

**ខ-បញ្ហាដែលត្រូវផ្ដោតការយកចិត្តទុកដាក់ក្នុងការពិសោធន៍:** ជាប្រភេទដែលកំពុងរងនូវការគំរាមកំហែង និងមានសក្ដានុពលក្នុងការប្រើប្រាស់នៅប្រទេសយើង ហើយលក្ខណៈសិរីរៈរបស់វាមានសេចក្ដីរាយការណ៍មកខុសៗគ្នាៈ គ្រាប់ពពេលនៅតាមបណ្ដាប្រទេសខ្លះ អាចធ្វើការសសំងួតដកហូតជាតិទឹក ហើយអាចរក្សាទុកបានរយៈពេលរហូតដល់ ៦ខែ ដោយឡែកនៅប្រទេសកម្ពុជា ជាទូទៅគ្រាប់ពពេលជាគ្រាប់នៃ គ្រួសារDipterocapacea ដែលភាគច្រើនតែងគិតថា មិនអាចរក្សាទុកបានយូរលើសពី ១-២អាទិត្យឡើយ ។

**គ-ការបេះប្រមូល:**យើងបានប្រមូលគ្រាប់ពពេលដោយការអង្រួនដើមមេ ហើយក្រាលក្រណាត់នៅកោមដើម ដើម្បីប្រមូលយកផ្លែទុំដែលធ្លាក់ បន្ទាប់មកយើងច្រកគ្រាប់ទាំងនោះក្នុងបាវ ដោយក្នុង១បាវមានផ្លែប្រហែល ៦គីឡូក្រាម ហើយស្តុកទុកជាបណ្ដោះអាសន្ននៅក្នុងម្លប់រយៈពេល ២យប់ ទើបដឹកមកបន្ទប់ពិសោធន៍គ្រាប់ពូជ ដោយមានការគ្របដណ្ដប់ក្រណាត់ពីលើមួយជាន់ទៀត ។ នៅក្នុងបន្ទប់បិសោធន៍ យើងបានកាត់ស្លាបវាចេញដោយដៃ អស់រយៈពេល ៥ថ្ងៃទៀត ទើបចាប់ផ្ដើមពិសោធន៍ ហើយលទ្ធផលទទួលបានដូចតទៅ:

**ឃ-ការពិសោធន៍:**

**ឃ.១-ប្រវត្តិរបស់គ្រាប់:**

| | |
|---|---|
| .កាលបរិច្ឆេទនៃការប្រមូល: | ២៨ មេសា ២០០៣ |
| .ទីកន្លែងប្រមូលគ្រាប់: | បាក់ស្នា ស្រុកសន្ទុក ខេត្តកំពង់ធំ |
| .ទំងន់គ្រាប់: | ៨២០ក្រាម ក្នុង១០០០គ្រាប់ ឬ១២១៨គ្រាប់ ក្នុង១គីឡូក្រាម |
| .ការកាត់គ្រាប់ពិនិត្យ: | ៩៥% |

**ឃ.២-លទ្ធផលនៃការពិសោធន៍ដំបូង**

| កាលបរិច្ឆេទនៃការពិសោធន៍ | កំរិតសំណើមដំបូង | ការធ្វើប្រព្រឹត្តិកម្ម | អត្រាដំណុះ% | រយៈពេលឃើញមានដំណុះដំបូង |
|---|---|---|---|---|
| ០២ ខែឧសភា ២០០៣ | ២៩.៦៦% | ត្រាំទឹកធម្មតាមួយយប់ | ៩៤.៥០% | ១៣ថ្ងៃ មានដំណុះ ៤៨% |



**រូបទី១៨**-ដំណុះកូនពពេលក្នុងពេលពិសោធន៍




**រូបទី១៩**-លក្ខណៈដំណុះរបស់កូនពពេល

### ឃ.៣-ការដកហូតជាតិទឹក

បន្ទាប់ពីទទួលបាននូវទិន្នន័យនៃការពិសោធន៍ដំបូងរួចហើយ យើងបានបែងចែកគ្រាប់ពពេលទាំងអស់ជា ៧ផ្នែកហើយយកទៅដកហូតជាតិទឹក តាមកំរិតសំណើមផ្សេងៗគ្នាៈ ២៥% ២០% ១៥% ១២% ៩% ៦% ។ គោលបំណងសំខាន់នៃការដកហូតជាតិទឹកនេះគឺដើម្បីរក្សា ទុកគ្រាប់ឱ្យបានយូរ ជៀសវាងពីការរាតត្បាតរបស់ផ្សិតចម្រៃ ដែលតែងកើតមានឡើងចំពោះគ្រាប់ដែលមានកំរិតសំណើមខ្ពស់ ។ បន្ទាប់ពីដកហូតជាតិទឹកបានត្រឹមត្រូវរួចហើយ យើងបានយកគ្រាប់ទាមងនេះទៅបណ្ដុះ ដើម្បីរកឱ្យឃើញនូវកំរិតសំណើមដែលសមស្របសំរាប់ការរស់រានរបស់គ្រាប់ (លទ្ធផលលំអិតនៃការដកហូតជាតិទឹកមានជូននៅក្នុងតារាងឧបសម្ព័ន្ធ) ។ អត្រាដំណុះបន្ទាប់ពីការដកហូតជាតិទឹករបស់គ្រាប់ពពេលទទួលបានដូចតទៅៈ

**លទ្ធផលនៃការដកហូតជាតិទឹករបស់គ្រាប់ពពេល**

| កាលបរិច្ឆេទនៃការពិសោធន៍ | កំរិតសំណើមគោលដៅ | កំរិតសំណើមជាក់ស្ដែង | អត្រាដំណុះ % |
|---|---|---|---|
| 02/05/2003 | គ្រាប់ស្រស់ | 29.66% | 94.5% |
| 12/05/2003 | 25% | 25.59% | 86% |
| 12/05/2003 | គ្រាប់សំរាប់ផ្ទៀងផ្ទាត់ (Control) | 30.71% | 93% |
| 21/05/2003 | 20% | 20.45% | 72% |
| 21/05/2003 | គ្រាប់សំរាប់ផ្ទៀងផ្ទាត់ (Control) | 30.23% | 86.5% |
| 26/05/2003 | 15% | 16.94% | 12% |
| 26/05/2003 | គ្រាប់សំរាប់ផ្ទៀងផ្ទាត់ (Control) | 30.95% | 84% |
| 02/06/2003 | 12% | 12.25% | 0% |
| 02/06/2003 | គ្រាប់សំរាប់ផ្ទៀងផ្ទាត់ (Control) | 30.05% | 91% |
| 05/06/2003 | 9% | 10.17% | 0% |
| 05/06/2003 | គ្រាប់សំរាប់ផ្ទៀងផ្ទាត់ (Control) | 30.47% | 83% |
| 12.06/2003 | 6% | 7.08% | 0% |
| 12/06/2003 | គ្រាប់សំរាប់ផ្ទៀងផ្ទាត់ (Control) | 30.04% | 88% |

**សន្និដ្ឋានៈ** បើទោះជាលទ្ធផលខាងលើ បង្ហាញថាជាតិទឹកខ្លះអាចអនុញ្ញាតឱ្យយើងដកហូតបានក៏ដោយ ក៏អត្រារស់របស់គ្រាប់ដែលទទួលបាននោះ មានការថយចុះដែរ បើប្រៀបធៀបទៅនឹងអត្រាដំណុះ របស់គ្រាប់សំរាប់ផ្ទៀងផ្ទាត់ ជាពិសេសទៅទៀតនោះចំពោះគ្រាប់ដែលជាតិទឹកនៅសល់តិចជាង២០% អត្រារស់របស់គ្រាប់បានធ្លាក់ចុះយ៉ាងលឿន ។ ដូចនេះ គ្រាប់ពពេលមិនធន់ទ្រាំនឹងការដកហូតជាតិទឹកទេ ។ កំរិតអប្បបរិមានៃសំណើមដែលអាចធានាការរស់រានរបស់ គ្រាប់គឺៈ ២០%ដែលអាចឱ្យគ្រាប់នៅរស់បាន ៧២% ក្នុងខណៈដែលគ្រាប់ស្រស់សំរាប់ផ្ទៀងផ្ទាត់នៅមានជីវិត ៨៦.៥០% ។

**ឃ.៤-ការថែរក្សាទុកដាក់:** បន្ទាប់ពីដកហូតជាតិទឹកបានរួចរាល់ហើយ យើងបានយកវាទៅថែរក្សាទុកក្នុងពីរលក្ខខណ្ឌ គឺះ បន្ទប់ធម្មតា និង ទូរដែលមានសីរុណ្ហភាព១០°C ដើម្បីតាមដានដំណុះរបស់វា។ រីឯលទ្ធផលនៃដំណុះ ដែលទទួលបានបន្ទាប់ពីការថែរក្សាទុកដាក់ យើងទទួលបានដូចតទៅ:

**លទ្ធផលនៃការថែរក្សាទុកដាក់**

| កំរិតសំណើមកំណត់ | កំរិតសំណើមជាក់ស្តែងមុនការថែរក្សា | លក្ខខណ្ឌនៃការថែរក្សាទុកដាក់ | រយៈពេលនៃការថែរក្សាទុកដាក់ | កំរិតសំណើមជាក់ស្តែងបន្ទាប់ពីការថែរក្សា | អត្រាដំណុះ% |
|---|---|---|---|---|---|
| គ្រាប់ស្រស់ | 30.32% | ទូរដែលមានសីតុណ្ហភាព 10°C | 1 អាទិត្យ | 30.00% | 93% |
| | | | 2 អាទិត្យ | 30.09% | 84% |
| | | | 1 ខែ | 29.96% | 84% |
| | | | 3 ខែ | 29.29% | 77% |
| | | | 6 ខែ | | |
| | | | 9 ខែ | | |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 29.53% | 89% |
| | | | 2 អាទិត្យ | 29.82% | 89% |
| | | | 1 ខែ | 27,76% | 69% |
| | | | 3 ខែ | 30.29% | 45% |
| | | | 6 ខែ | | |
| | | | 9 ខែ | | |
| 25% | 25.59% | ទូរដែលមានសីតុណ្ហភាព 10°C | 1 អាទិត្យ | 23.70% | 81% |
| | | | 2 អាទិត្យ | 25.24% | 78% |
| | | | 1 ខែ | 25.50% | 74% |
| | | | 3 ខែ | 25.63% | 52% |
| | | | 6 ខែ | | |
| | | | 9 ខែ | | |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 25.09% | 84% |
| | | | 2 អាទិត្យ | 25.36% | 73% |
| | | | 1 ខែ | 25.74% | 62% |
| | | | 3 ខែ | 26.30% | 2% |

| | | | | | |
|---|---|---|---|---|---|
| | | | 6 ខែ | | |
| | | | 9 ខែ | | |
| 20% | 20.45% | ទូរដែលមាន សីតុណ្ហភាព 10°C | 1 អាទិត្យ | 20.32% | 26% |
| | | | 2 អាទិត្យ | 22.12% | 13% |
| | | | 1 ខែ | 20.11% | 6% |
| | | | 3 ខែ | 20.32% | 0% |
| | | | 6 ខែ | | |
| | | | 9 ខែ | | |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 20.49% | 43% |
| | | | 2 អាទិត្យ | 21.62% | 17% |
| | | | 1 ខែ | 20.24% | 0% |
| | | | 3 ខែ | 20.70% | 0% |
| | | | 6 ខែ | | |
| | | | 9 ខែ | | |
| 15% | 16.94% | ទូរដែលមាន សីតុណ្ហភាព 10°C | 1 អាទិត្យ | 17.59% | 0% |
| | | | 2 អាទិត្យ | 16.13% | 0% |
| | | | 1 ខែ | 16.08% | 0% |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 17.64% | 0% |
| | | | 2 អាទិត្យ | 15.98% | 0% |
| | | | 1 ខែ | 16.02% | 0% |
| 12% | 12.25% | ទូរដែលមាន សីតុណ្ហភាព 10°C | 1 អាទិត្យ | 12.36% | 0% |
| | | | 2 អាទិត្យ | 12.36% | 0% |
| | | | 1 ខែ | 12.46% | 0% |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 12.52% | 0% |
| | | | 2 អាទិត្យ | 12.41% | 0% |
| | | | 1 ខែ | 12.29% | 0% |
| 9% | 10.17% | ទូរដែលមាន សីតុណ្ហភាព 10°C | 1 អាទិត្យ | 10.22% | 0% |
| | | | 2 អាទិត្យ | 10.12% | 0% |

| | | | | | |
|---|---|---|---|---|---|
| | | | 1 ខែ | 10.05% | 0% |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 10.13% | 0% |
| | | | 2 អាទិត្យ | 10.25% | 0% |
| | | | 1 ខែ | 10.28% | 0% |
| 6% | 7.08% | ទូរដែលមាន សីតុណ្ហភាព 10°C | 1 អាទិត្យ | 7.10% | 0% |
| | | | 2 អាទិត្យ | 6.71% | 0% |
| | | | 1 ខែ | 7.00% | 0% |
| | | បន្ទប់ធម្មតា | 1 អាទិត្យ | 7.11% | 0% |
| | | | 2 អាទិត្យ | 7.06% | 0% |
| | | | 1 ខែ | 7.82% | 0% |

**សន្និដ្ឋាន:** បើទោះជាលទ្ធផលខាងលើបង្ហាញថាគ្រាប់ពពេលស្រស់អាចថែរក្សាទុកបាន មិនអាចថែរក្សាទុកបានយូរ

**និងយោបល់ចំពោះការធ្វើលទ្ធកម្មគ្រាប់ពូជ:** ការប្រមូលគ្រាប់ពពេលគួរធ្វើឡើងឱ្យបានទាន់ពេលវេលា ប្រសិនបើអាចគួរប្រមូលដោយការអង្រួនដើមដោយមានក្រាលក្រណាត់ពីក្រោមដើម្បីត្រងយកគ្រាប់ដែលធ្លាក់ មិនគួរប្រមូល នៅនឹងដីទេព្រោះវាអាចនាំឱ្យមានការចំលងការរាតត្បាតរបស់ផ្សិតចង្រៃ។

បន្ទាប់ពីប្រមូលបានមក គ្រាប់ទាំងនេះគួរតែធ្វើការវេចខ្ចប់ឱ្យបានត្រឹមត្រូវ ដោយគួរតែប្រើស្បោងប្លាស្ទិចវេចខ្ចប់វាហើយបត់មាត់ស្បោងដោយទុកឱ្យមានខ្យល់អាចចេញចូលបាន រួចច្រកស្បោងទាំងនេះចូលក្នុងស្បោងក្រណាត់មួយជាន់ទៀត រួចតំរៀបវាកុំឱ្យគរលើគ្នា ដោយទុកឱ្យមានប្រឡោះឃ្លាតពីគ្នាដើម្បីឱ្យមានខ្យល់អាចចេញចូល រួចគ្របក្រណាត់ពីលើមួយជាន់ទៀតមុននឹងដឹកមកានទីកន្លែងគោលដៅ។

រីឯការកាត់ស្លាប យើងអាចធ្វើមុនការដឹកជញ្ជូននៅក្នុងព្រៃក៏បាន ឬក្រោយការដឹកជញ្ជូននៅទីកន្លែងគោលដៅក៏បានតែការណ៏នេះត្រូវធ្វើឱ្យបានរួសរាន់ តាមការដែលអាចធ្វើទៅបាន ព្រោះការអូសបន្លាយការកាត់ស្លាបនេះ វាឈានដល់ការអូសបន្លាយការទុកដាក់ ដែលអាចជាហេតុ នាំឱ្យគ្រាប់ឆាប់ខូច។

យើងមិនគួរដកហូតជាតិទឹកពីគ្រាប់ពពេលទេ (សូមពិនិត្យសទ្ធផលនៃការដកហូតជាតិទឹកខាងលើ) គ្រាប់ដែលប្រមូលបានហើយ គួរសាបទៅក្នុងថ្នាលភ្លាមរួចរង់ចាំកូនពពេលដែលដុះឡើង សឹមគាស់យកិមកដាក់ក្នុងស្បោងបណ្តុះ។

ក្នុងករណីដែលយើងចង់ធ្វើការទុកដាក់ គ្រាប់ពពេលដែលបេះ នឹងប្រឡេះហើយ ត្រូវវេចខ្ចប់នឹងស្បោងប្លាស្ទិចឱ្យបានជិតល្អ រួចស្តុកទុកក្នុងទូរដែលមានសីតុណ្ហភាពប្រហែល10°C នោះយើងអាចទុកបានលើសរយៈពេល៣ខែ។ ក្នុងករណីដែលទូរស្តុកខាងលើ មិនអាចរកបាន នោះការស្តុកទុកមិនអាចលើសពីរយៈពេល១ខែ ឡើយ ដោយធ្វើការវេចខ្ចប់វាដូចគ្នានេះដែរ។

## ៥-ប្រភេទជ័រចុង (*Shorea guiso*)

### ក-លក្ខណៈទូទៅ :

ជ័រចុងជារុក្ខជាតិមានទំហំធំ ប្រជាជនយើងនិយមយកជ័ររបស់វាទៅធ្វើជាគ្រឿងលាបលន ទូក និងសំភារៈផ្សេងៗ។ ផ្លែរបស់វាមានទំហំតូចល្មមប៉ុនផ្លែគរគី តែជាទូទៅវាមានស្លាបប្រាំ ។ ជ័រចុងចាប់ផ្ដើមផ្កា នៅខែមករា-កុម្ភៈ និង មានផ្លែទុំនៅខែមេសា-ឧសភា ។យើងអាចប្រមូលគ្រាប់ជ័រចុង នៅនឹងដីពេលវាទុំជ្រុះ ឬយើងអាចឡើងអង្រន់ដើមដើម្បីប្រមូលគ្រាប់ដែលជ្រុះ ឬធ្វើការកាត់មែកដែលមានផ្លែទុំ រួចបេះយកផ្លែដែលទុំ ។




រូបទី២០-ផ្លែជ័រចុងពេលនៅខ្ចី



រូបទី២១-ផ្លែជ័រចុងពេលទុំ

### ខ-ការបេះប្រមូល ការវេចខ្ចប់ និងការដឹកជញ្ជូន :

យើងបានប្រមូលផ្លែជ័រចុងនៅនឹងដី រួចយកទៅកាត់ស្លាបចេញ និងវេចខ្ចប់វាក្នុងស្បោងប្លាស្ទិច ដែលមានបរិមាណជាមធ្យម ១.៥ គ ក្រ ក្នុង១ស្បោង ហើយបត់មាត់ស្បោងដោយទុកឱ្យមានខ្យល់ចេញចូលបានផង រួចច្រកវាក្នុងស្បោងក្រាណាត់មួយជាន់ទៀត រួចដឹកជញ្ជូនវាមកកាន់បន្ទប់ផពិសោធន៍ ដោយមានគ្របដណ្ដប់ផ្ទាំងក្រណាត់ពីលើបន្ថែមទៀត ដើម្បីការពារការបាត់បង់នៃសំណើមរបស់គ្រាប់ ក្នុងពេលដឹកជញ្ជូន ។



រូបទី២២-ការវេចខ្ចប់គ្រាប់ជ័រចុងមុននឹងដឹកជញ្ជូន




រូបទី២៣-ការគ្របដណ្ដប់គ្រាប់ មុនពេលដឹកជញ្ជូន

### គ-ការពិសោធន៍គ្រាប់ជ័រចុងៈ

ដើម្បីស្វែងយល់អំពីលក្ខណៈសរីរៈ និងដើម្បីធ្វើពិសោធន៍ក្នុងការថែរក្សាទុកដាក់វា យើងបាន ប្រមូលគ្រាប់ជ័រចុងមួយចំនួនយកមកសិក្សាៈ

#### គ-១-ប្រវត្តិរបស់គ្រាប់

-កាលបរិច្ឆេទនៃការប្រមូលគ្រាប់ៈ ២៤ មេសា ២០០២

-ទីកន្លែងប្រមូលគ្រាប់ៈស្ថានីយ៍ ៩៩ របស់សហគ្រាសកូឡិចស៊ីម

-បរិមាណគ្រាប់: ៧.៥ គ ក្រ

-ព្រឹត្តិការណ៍គួរកត់សំគាល់: ភ្លៀង និងខ្យល់ មុនពេលប្រមូលគ្រាប់ពូជ

**គ-២-ការធ្វើពិសោធន៍ដំបូង:**

នៅក្នុងបន្ទប់ពិសោធន៍ យើងបានយកគ្រាប់ជ័រចុងទៅធ្វើពិសោធន៍ ដើម្បីឱ្យមានការជឿជាក់លើគុណភាពគ្រាប់ដែលយកមកសិក្សា ។ លទ្ធផលដែលយើងទទួលបានគឺ:

-កំរិតសំណើមដំបូង : ៣៤.៤០%

-ទំងន់គ្រាប់ : ៥៣២.៤០ ក្រ . ១០០០ គ្រាប់ ឬ ១៨៧៨ គ្រាប់ . គ ក្រ

-ការកាត់គ្រាប់ពិនិត្យភាពរស់ : ៩០%

-ប្រព្រឹត្តិកម្មគ្រាប់ពូជ : គ្មាន

-អត្រាដំណុះដំបូង: ៨១.៥០%

**គ-៣-ការសំងួតគ្រាប់ជ័រចុង :**

ដើម្បីមានមូលដ្ឋានក្នុងការថែរក្សា និងទុកដាក់គ្រាប់ជ័រចុង យើងបានធ្វើការបញ្ចុះសំណើមវាតាមកំរិត លំដាប់លំដោយ និងវាយតំលៃលើអត្រាដំណុះរបស់វា តាមរយៈការបណ្តុះឡើងវិញ ហើយទទួលបានលទ្ធផល:

លទ្ធផលនៃការបញ្ចុះសំណើមគ្រាប់ជ័រចុង

| កំរិតសំណើម ដំបូង | កំរិតសំណើមកំណត់ | ពេលចាប់ផ្តើមសំងួត | ពេលបញ្ចប់សំងួត | សំណើមជាក់ស្តែងបន្ទាប់ពីសំងួត | អត្រាដំណុះបន្ទាប់ពីសំងួត |
|---|---|---|---|---|---|
| ៣៤.៤០% | គ្រាប់ស្រស់ | | | | ៨១.៥០% |
| | ២៥% | ៣០-០៤-២០០២ | ០១-០៥-២០០២ | ២៦.៧០% | ៧៩% |
| | ២០% | ៣០-០៤-២០០២ | ០២-០៥-២០០២ | ២១.៨៥% | ៣២% |
| | ១៥% | ៣០-០៤-២០០២ | ០២-០៥-២០០២ | ១៦.៦១% | ១.៥% |
| | បណ្តុះត្រួតពិនិត្យ | | ០២-០៥-២០០២ | ៣២.២% | ៧៦% |
| | ៥% | ៣០-០៤-២០០២ | ០៣-០៥-២០០២ | ៩.៧០% | ០% |

**គ-៤-ការថែរក្សានិងទុកដាក់:**

បន្ទាប់ពីសំងួតរួចហើយ យើងបានយកគ្រាប់ទាំងនេះទៅថែរក្សាទុកក្នុងពីរកន្លែង ដែលមានលក្ខខណ្ឌសីតុណ្ហភាពផ្សេងគ្នា

-បន្ទប់ត្រជាក់ដែលមានសីតុណ្ហភាព ១០°c

-បន្ទប់ធម្មតា

នៅក្នុងរយៈពេលកំណត់ យើងបានធ្វើការត្រួតពិនិត្យសំណើម និងបណ្តុះវាឡើងវិញ ដើម្បីត្រួតពិនិត្យភាពរស់របស់វា ។ លទ្ធផលនៃការត្រួតពិនិត្យ យើងទទួលបានដូចខាងក្រោម:

# លទ្ធផលនៃការទុកដាក់ និងថែរក្សាគ្រាប់ជ័រចុង

| កំរិតសំណើមកំណត់ | សំណើមជាក់ស្តែងមុនពេលទុកដាក់ | លក្ខខណ្ឌនៃការទុកដាក់ | រយៈពេលនៃការទុកដាក់ | កំរិតសំណើមក្រោយការទុកដាក់ | អត្រាដំណុះក្រោយការទុកដាក់ |
|---|---|---|---|---|---|
| ៣៤% | ៣៤.៤0% | ទូរ10°C | ២ អាទិត្យ | ៣៥.២៣% | ៣.៥% |
| | | | ១ ខែ | ៣៤.៧៦% | 0% |
| | | បន្ទប់ធម្មតា | ២ អាទិត្យ | ៣៥.៩៥% | 0% |
| | | | ១ ខែ | ៣៤.៣១% | 0% |
| | | | ៣ ខែ | ៣២.៤២% | 0% |
| ២៥% | ២៦.៧% | ទូរ10°C | ២ អាទិត្យ | ២៦.៧៧% | ៩.៥% |
| | | | ១ ខែ | ២៤.៩៨% | 0% |
| | | បន្ទប់ធម្មតា | ២ អាទិត្យ | ២៧.៧៨% | 0% |
| | | | ១ ខែ | ២៧.៦២% | 0% |
| | | | ៣ ខែ | ២៦.៩៧% | 0% |
| ២0% | ២១.៨៥% | ទូរ10°C | ២ អាទិត្យ | ២២.៤៩% | 0% |
| | | | ១ ខែ | ២១.៥៩% | 0% |
| | | បន្ទប់ធម្មតា | ២ អាទិត្យ | ២២.៧៧% | 0% |
| | | | ១ ខែ | ២២.0២% | 0% |
| | | | ៣ ខែ | ២១.៦៧% | 0% |
| ១៥% | ១៦.៦១% | ទូរ10°C | ២ អាទិត្យ | ១៧.២៨% | 0% |
| | | | ១ ខែ | ១៦.២៥% | 0% |
| | | បន្ទប់ធម្មតា | ២ អាទិត្យ | ១៧.១៤% | 0% |
| | | | ១ ខែ | ១៦.៣១% | 0% |
| | | | ៣ ខែ | ១៥.៣៣% | 0% |
| ៥% | ៩.៧0% | ទូរ10°C | ២ អាទិត្យ | ១0.0៣% | 0% |
| | | | ១ ខែ | ៩.៦១% | 0% |
| | | បន្ទប់ធម្មតា | ២ អាទិត្យ | ៩.៩៨% | 0% |
| | | | ១ ខែ | ៩.៥៥% | 0% |
| | | | ៣ ខែ | ៩.0៦% | 0% |

**សេចក្តីសន្និដ្ឋាន និងយោបល់ចំពោះការធ្វើលទ្ធកម្មគ្រាប់ជ័រចុង:**

**–**ជ័ចុងជាប្រភេទឈើ ដែលគ្រាប់របស់វាមានលក្ខណៈ Recalcitrant ( មិនអាចទុកបានយូរ) ។

-យើងមិនគួរប្រមូលគ្រាប់ជ័រចុងដោយផ្ទាល់នឹងដីទេ ជាពិសេសនៅពេលដែលសំណើមរបស់បរិយាកាសមានកំរិតខ្ពស់ ព្រោះវាងាយនឹងរងនូវការរាតត្បាតពីផ្សិតចង្រៃណាស់ បើទោះជាក្នុងការបេះប្រមូល និងការទុកដាក់ គ្រាប់ឈើប្រភេទនេះ ពុំឃើញមានការបំផ្លាញពីសត្វល្អិតក៏ដោយ ក៏វាងាយនឹងរងនូវការបំផ្លាញពីផ្សិតណាស់ ។

- គ្រាប់របស់វា បន្ទាប់ពីប្រមូលបានភ្លាម គួរយកទៅសាបក្នុងថ្នាលឱ្យបានទាន់ពេលវេលាភ្លាម មិនគួរនឹងថែរក្សាវាទុកដោយប្រការ ណាមួយឡើយ ។

**៦-ប្រភេទម្រុំ** (*Moringa oleifera* Lam.)

**ក-លក្ខណៈទូទៅ និងការប្រើប្រាស់**

ម្រុមជារុក្ខជាតិដែលមានទំហំមធ្យម មានកំពស់ពី ៣-១០ម៉ែត្រ ។ ផ្លែម្រុមមានរាងវែង មានពណ៌បៃតងពេលខ្ចី និងពណ៌លឿងស្រស់ ពេលវាចាប់ផ្តើមទុំភ្លាម និងពណ៌ត្នោតប្រផេះ ពេលវាទុំយូរ ។ នៅខាងក្នុងផ្លែមានផ្ទុកគ្រាប់ពី ៥-២០គ្រាប់ ។ គ្រាប់មានសភាពស្តោត និងទំហំ ពី ៥-១២មីល្លីម៉ែត្រ ហើយគ្រាប់នេះ ស្រោបទៅដោយ សន្ទះពណ៌សស្តើង ហើយសន្ទះស្តើងនេះបានភ្ជាប់គ្រាប់ទៅនឹងផ្លែបានយ៉ាងជាប់ល្អ ។ ប្រជាជនយើងនិយមដាំវានៅជុំវិញភូមិដ្ឋាន ដើម្បី ធ្វើជាបន្លែ បង្កាផ្សេងៗ: ផ្កា ស្លឹក និង ផ្លែខ្ចី ធ្វើជាបន្លែសំរាប់ស្ល ។ ស្លឹកវាទោះចាស់ ឬខ្ចី អាចធ្វើជាចំណីសត្វគោ ក្របីបាន ។ សំបករបស់វា ត្រូវបានគ្រូឱសថបុរាណយកទៅផ្សំជាថ្នាំកំលាំងសំរាប់ស្ត្រីដែលទើបឆ្លងទន្លេរួច ។



រូបទី២៤-ស្លឹក និងដើមម្រុំ



រូបទី២៥-ផ្កានិងស្លឹកម្រុំ



រូបទី២៦-ផ្លែម្រុំពេលទុំ



រូបទី២៧-ផ្លែម្រុំប្រេះពេលទុំ




រូបទី២៩-គ្រាប់ម្រុំដែលប្រឡេះរួច

**ខ-ការពិសោធន៍គ្រាប់ម្រុំ**

ដើម្បីស្វែងយល់អំពីលក្ខណៈសរីរៈរបស់គ្រាប់ម្រុម និងដើម្បីមានមូលដ្ឋានក្នុងការថែរក្សា និងទុកដាក់វា យើងបានប្រមូលផ្លែ ម្រុំមួយចំនួនយកមកធ្វើការសិក្សា ហើយលទ្ធផលយើងបានធ្វើការកត់ត្រាទុកដូចតទៅ:

**ខ.១-ប្រវត្តិ:**

-កាលបរិច្ឆេទនៃការប្រមូលផ្លែ:២៣ ឧសភា ២០០២

-ទីកន្លែងប្រមូលផ្លែ: ភូមិតាព្រហ្ម ឃុំព្រែកឯង ស្រុកគៀនស្វាយ ខេត្តកណ្តាល

-ចំនួនផ្លែ: ២៥០ផ្លែ

-ទំងន់គ្រាប់សរុបដែលប្រឡេះហើយ: ០.៥ គ ក្រ

**ខ.២-ការពិសោធន៍ដំបូង:**

-កាលបរិច្ឆេទនៃការធ្វើពិសោធន៍ដំបូង: ២៤ ឧសភា ២០០២

-កំរិតសំណើមដំបូង : ១២.៣៤%

-ទំងន់គ្រាប់: ២៣៧.៧០ ក្រ . ១០០០គ្រាប់ ឬ ៤២០៧ គ្រាប់ . គ ក្រ

-ប្រព្រឹត្តិកម្មគ្រាប់: គ្មាន

-អត្រាដំណុះដំបូង: ៩១%

**គ-ការថែរក្សា និងទុកដាក់គ្រាប់:**

បន្ទាប់ពីរកឃើញនូវទិន្នន័យមួយចំនួនរួចមក យើងបានវេចខ្ចប់គ្រាប់ទាំងនេះដោយថង់ប្លាស្ទិចបិទជិត និងថែរក្សាវាទុកក្នុងពីរលក្ខខណ្ឌ :

-ក្នុងបន្ទប់ត្រជាក់ ដែលមានសីតុណ្ហភាព ១០ °C

-ក្នុងបន្ទប់ធម្មតា ដែលមានសីតុណ្ហភាព ២៥°C- ២៨ °C

នៅរយៈពេលកំណត់ យើងធ្វើការត្រួតពិនិត្យសំណើម និងបណ្ដុះវាឡើងវិញ ហើយទទួលបានលទ្ធផល :

**លទ្ធផលនៃការថែរក្សាគ្រាប់ម្រុំ**

| កំរិតសំណើមដំបូង | រយៈពេល នៃការថែរក្សា | លក្ខខណ្ឌ នៃការថែក្សា | កំរិតសំណើមជាក់ស្ដែង បន្ទាប់ពីការថែរក្សា | អត្រាដំណុះ (មិនធ្វើប្រព្រឹត្តិកម្ម) |
|---|---|---|---|---|
| ១២.៣៤% | | គ្រាប់ស្រស់ | ១២.៣៤% | ៩១% |
| | ២ សប្ដាហ៍ | បន្ទប់ត្រជាក់ ១០°C | ៨.៤០% | ៩០% |
| | | បន្ទប់ធម្មតា | ៩.០៥% | ៩២% |
| | ១ខែ | បន្ទប់ត្រជាក់ ១០°C | ៨.៨១% | ៩៥% |
| | | បន្ទប់ធម្មតា | ៨.៩១% | ៩៥% |
| | ៣ខែ | បន្ទប់ត្រជាក់ ១០°C | ៧.៨៩% | ៩២% |
| | | បន្ទប់ធម្មតា | ៨.១៥% | ៨៩% |
| | ៦ខែ | បន្ទប់ត្រជាក់ ១០°C | ៧.៦៤% | ៩២% |
| | | បន្ទប់ធម្មតា | ៨.៩០% | ៨៧% |
| | ៩ខែ | បន្ទប់ត្រជាក់ ១០°C | ៦.៥៦% | ៧៨% |
| | | បន្ទប់ធម្មតា | ៧.៣៩% | ៨១% |



**រូបទី៣០**-ដំណុះគ្រាប់ម្រុំបន្ទាប់ពីរក្សាទុក៣ខែ

**ការសន្និដ្ឋាន   និងយោបល់លើការធ្វើលទ្ធកម្មគ្រាប់ម្រុំ**

បើទោះបីជាការសំងួតរបស់វាមិនទាន់បានសិក្សាក៏ដោយ ក៏យើងអាចសន្និដ្ឋានបានថា គ្រាប់ម្រុមជាគ្រាប់ដែលមាន លក្ខណៈទំនោរទៅរកពពួកគ្រាប់ Orthodox ( គ្រាប់ដែលទុកបានយូរ) ហើយមានលក្ខណៈងាយស្រួលទាំងក្នុងការទុកដាក់ និងបណ្តុះ ( មិនមានការបំផ្លាញពីសត្វល្អិត និង ដាក់បណ្តុះដោយមិនចាំបាច់ធ្វើប្រព្រឹត្តិកម្ម) ។ តែប្រការដែលយើងគួរយកចិត្តទុកដាក់នោះគឺការប្រមូលផ្លែវាដែលទុំឱ្យទាន់ពេលវេលា ដើម្បីទទួលបាននូវគ្រាប់ដែលមានគុណភាពល្អប្រកបដោយអត្រាដំណុះ ខ្ពស់ ។

ពេលវេលាប្រមូលផ្លែដែលសមស្របបំផុត គឺពេលដែលផ្លែ វាចាប់ផ្តើមប្រែពណ៌ពីលឿងមកជាពណ៌ត្នោត ។

ការយឺតយ៉ាវក្នុងការប្រមូលផ្លែទុំ ធ្វើឱ្យផ្លែដែលទុំជ្រុលប្រេះបែក ហើយគ្រាប់ជ្រុះធ្លាក់មកដី ឬផ្លែទាំងនោះស្វិតជាប់នៅនឹងដើម តែគ្រាប់របស់វាចុះអន់គុណភាព ដោយអត្រាដំណុះចុះទាប ឬអាចនឹងត្រូវខូចខាតទាំងស្រុង ។

ដោយផ្អែកទៅលើតារាងនៃការសិក្សាស្រាវជ្រាវខាងលើ យើងឃើញថា ការទុកដាក់គ្រាប់ម្រុំ មិនទាក់ទងទៅនឹង សីតុណ្ហភាពនៃលក្ខខណ្ឌថែរក្សាឡើយ តែយើងក៏មិនគួរធ្វេសប្រហែសក្នុងការទុកដាក់វា ដោយគ្មានការថែទាំ និងយកចិត្តទុកដាក់ឡើយ ។

គ្រាប់ម្រុមដែលទើបនឹងប្រមូលបាន និងប្រឡេះចេញពីផ្លែហើយ គួរពិនិត្យសំណើមរបស់ វាឱ្យបានត្រឹមត្រូវ ហើយត្រូវដាក់ហាលសំដិលវាឱ្យស្ងួតល្មម រួចវេចខ្ចប់វាក្នុងស្បោងឱ្យបានជិតល្អ និងទុកដាក់ក្នុងម្លប់ ឱ្យបានសមរម្យ ។

យើងមិនគួរទុកដាក់គ្រាប់ម្រុមដែលមិនបានហាលសំដិលឱ្យស្ងួតល្អឡើយ ព្រោះក្នុងករណីនេះ គ្រាប់នឹងមានសំណើមខ្ពស់ដែលជាលក្ខខណ្ឌប្រកបសំរាប់ការរាតត្បាតនៃពពួកផ្សិតចង្រៃ ហើយនាំឱ្យគ្រាប់ត្រូវខូច ។